# ភូមិប្រាសាទ

## ឧទាហរណ៍ដីណៃលមុនសម័យអង្គរមួយនៅខេត្តកំពង់ធំ

ព្រាប ចាន់ម៉ារ៉ា
វិទ្យាស្ថានរ៉ៃយំ

បើយើងធ្វើដំណើរនៅលើផ្លូវជាតិលេខ៦ ពីកំណាត់ខាងលើក្រុងកំពង់ធំបន្តិចចុះមកទល់នឹងចំណុចស្គន់ យើងឃើញថានៅសងខាងខ្សែបន្ទាត់នោះមានបេតិកភណ្ឌបុរាណជាច្រើន។ផ្ទុយពីតំបន់អង្គរ នៅតំបន់នេះ ដីណៃលបុរាណភាគច្រើនសុទ្ធសឹងកើតឡើងនៅមុនសម័យអង្គរ។ បើយកក្រុមប្រាសាទសម្បូរណ៍ព្រៃគុកមកពោល ឃើញថាមិនត្រឹមតែជាប្រាសាទទោល ឬក៏ជាក្រុមតូចមួយនៅដាច់តែឯងឡើយ ប៉ុន្តែគឺជាក្រុមប្រាសាទដ៏ធំមានប្រាសាទរាប់រយ ដែលភាគច្រើនបង្អស់សាងឡើងក្នុងពេលជាមួយគ្នា ព្រមទាំងនៅក្នុងបរិបទប្រវត្តិសាស្ត្រនិងសិល្បៈជាមួយគ្នាផង ត្បិតក្រុមដ៏ធំនេះភ្ជាប់ខ្លួនទៅនឹងតំបន់ដ៏ត្រចះត្រចង់មួយនាសតវត្សទី៧ ដែលមានរាជធានីឈ្មោះ "ឦសានបុរ"។ នៅសម័យជាមួយគ្នានេះ ឬក៏ក្រោយមកនោះបន្តិច តំបន់នេះទាំងមូលក៏រីកធំធាត់ដូចមានដីណៃលប្រាសាទឬរចនាសម្ព័ន្ធខ្លះជាតឹកតាង។ លុះដល់ពេលដែលរាជធានីថ្មីៗថ្កើងខ្លាំងនៅតំបន់អង្គរ ក៏ទីនេះគេពុំដែលបោះបង់ចោលដែរ បើយោងទៅតាមសំណង់សាសនាសំខាន់ៗខ្លះ មាន "គុកនគរ" *(ស.វ.ទី១១)* ជាដើម *(សូមមើលប្លង់ទី១)*។

បើយកស្ថាបត្យកម្មដែលមើលមួយភ្លែតទៅហាក់ដូចជាគ្មានអ្វីពិសេស ក៏ការពិតគេត្រូវតែពិចារណាឲ្យដិតដល់។ ឧទាហរណ៍ "ប្រាសាទអណ្តែត" ដែលពុកផុយចាស់ទៅហើយនោះ ហើយដែលហាក់ដូចជាស្ថិតនៅទោលតែឯង តាមពិតទៅគឺគេធ្វើឡើងដើម្បីតម្កល់បដិមាព្រះហរិហរមួយអង្គ ដែលអ្នកប្រវត្តិសិល្បៈទាំងអស់ទទួលស្គាល់ថាជាស្នាដៃសិល្បៈដែលកម្រនឹងមានអ្វីមកប្រៀបប្រដូចបាន។

ជាអកុសល សំណល់ដែលយើងឃើញសព្វថ្ងៃគ្រាន់តែជាភាគមួយតូចប៉ុណ្ណោះនៃមរតកបុរាណ ដែលហិនហោចដោយប្រការផ្សេងៗ រាប់បញ្ចូលទាំងវិនាសកម្មដែលកើតឡើងក្នុងពីរបីទសវត្សកន្លងមកនេះ។

នៅទីនេះ ខ្ញុំនឹងលើកយកតែចំណុច "ភូមិប្រាសាទ" តូចមួយមកបង្ហាញ ពោលគឺដីណៃលបុរាណដែលនៅក្នុងបរិវេណ "វត្តប្រាសាទ" និងនៅក្បែរៗ វត្តនេះ។

## បរិបទប្រវត្តិសាស្ត្រ

ថ្វីត្បិតតែយើងមានទិន្នន័យតិចតួចស្តួចស្តើងតាមរយៈសិលាចារឹក ក៏យើងអាចដឹងថាចំណុចដែលលើកមកលាតត្រដាងនេះមានភាពថ្កុំថ្កើងនៅរវាងស.វ.ទី៧និងទី៨។ ឧទាហរណ៍ បើចុះមកខាងនិរតី ប្រមាណ៣គីឡូម៉ែត្រ មានដីណៃលបុរាណមួយនៅក្បែរភូមិត្នោតជុំហៅថា "គុកកំបុត" (ឬគុកខាងជើង) ដែលកើតឡើងពីស.វ.ទី៧ ហើយបើបន្តចុះមកខាងត្បូងនោះប្រហែលជាង ៤០គីឡូម៉ែត្រទៀត ក៏មានដីណៃលបុរាណស្ថិតក្នុងសម័យជាមួយគ្នានេះដែរហៅថា "គុកត្រពាំងស្រុក" *(រូបលេខ១)*។ បើឡើងទៅខាងជើងវិញក៏មានដីណៃលស្ថិតនៅស.វ.ទី៧ដូចគ្នា ឧទាហរណ៍កូនប្រាសាទមួយដែលស្ថិតនៅក្នុងវត្តពោធិវាំង *(រូបលេខ២)*។


ប្លង់ទី១
សម្បូណ៌ព្រៃគុក
ប្រា.អន្ទង់ណ្តូក
ខេត្ត កំពង់ធំ
ក្រុងកំពង់ធំ
គោករកា
ទួលវិហារ
ពោធិវាំង
ភូមិប្រាសាទ
ត្នោតជុំ
ខេត្តកំពង់ឆ្នាំង
គុកនគរ
គុកក្រពាំងស្រុក
អំពិលទ្វារ
ស្គន់
ទៅកំពង់ចាម
ទៅភ្នំពេញ
ខេត្ត កំពង់ចាម
០ ១០ ២០
គីឡូម៉ែត្រ
កំណត់សំគាល់៖
ប្រាសាទសម័យអង្គរ
ប្រាសាទសម័យមុនអង្គរ
ទីរួមខេត្ត, ទីប្រជុំជន
ផ្លូវជាតិលេខ៦
ផ្លូវខេត្ត
ព្រំប្រទល់ខេត្ត



រូបលេខ១១



រូបលេខ១២

## ក្រុមប្រាសាទភូមិប្រាសាទ

តួប៉មប្រាសាទដែលនៅមានរូបរាងឈរនៅឡើយមានឈ្មោះបច្ចុប្បន្ននេះថា “ប្រាសាទភូមិប្រាសាទ ”។ តាមពិតទៅ ដោយសារប្រាសាទនេះគេភ្លេចឈ្មោះដើម ក៏អ្នកស្រុកទម្លាប់ហៅថា “ប្រាសាទ” ដូច្នេះ (រូបលេខ១៣_៤)។ រីឯវត្តដែលមកតាំងនៅទីនោះតាំងពីសម័យកណ្ដាលមកក៏ហៅឈ្មោះថាវត្ត ប្រាសាទដូចគ្នា។ មិនតែប៉ុណ្ណោះ ភូមិទាំងមូលនោះក៏គេឲ្យឈ្មោះថា ភូមិប្រាសាទ ។

កាលពីឆ្នាំ ២០០០ កញ្ញាភិន វិជ្ជាសច្ចរា, លោកស៊ិន សុវណ្ណរ័ត្ន ព្រមទាំងខ្លួនខ្ញុំផ្ទាល់បានធ្វើការងារជាមួយគ្នា ដើម្បីពិពណ៌នាលម្អិតលើប្រាសាទនេះម្តងហើយ ក្នុងក្របខ័ណ្ឌសារណាបញ្ចប់ការសិក្សានៅមហាវិទ្យាល័យបុរាណវិទ្យា[១]។ សារណានោះផ្អែកមូលដ្ឋានលើការស្រាវជ្រាវដល់ទីកន្លែងផ្ទាល់ព្រមទាំងលើការសិក្សាស្រាវជ្រាវដែលមានពីមុនមក ដែលមានដូចតទៅ ៖

ការរៀបរាប់ជាដំបូងអំពីប្រាសាទទាំងមូលមាន ៖

- Aymonier, E., 1900, *Le Cambodge*, I, Ernest Leroux, Paris, p.369-370.
- Lunet de Lajonquière, E., 1902, *Inventaire descriptif des monuments du Cambodge,* I, Ernest Leroux, Paris, p.213-215.

[១] *ភូមិប្រាសាទ ដំណែលបុរាណនិងកិច្ចប្រតិបត្តិ*, ព្រាប ចាន់ម៉ារ៉ា, ភិន វិជ្ជាសច្ចរា, ស៊ិន សុវណ្ណរ័ត្ន ឆ្នាំ២០០០ (ពុំបានផ្សព្វផ្សាយជាទូទៅ)។



រូបលេខ១៣



រូបលេខ១៤

បន្ទាប់មកមានសម្រង់ប្លង់និងការរៀបរាប់អំពីស្ថាបត្យកម្មលម្អិតដែលធ្វើដោយ ៖

- Parmentier, H., 1927, *L'art khmèr primitif,* Vanoest, Paris, tome premier (texte) : p.183-186; tome second (planches) : Pl. LXXVI, LXXIX, LXXX.

រីឯសិលាចារឹកជាភាសាខ្មែរបុរាណនិងសំស្ក្រឹតរលុបស្ទើរបាត់ ដែលមាននៅលើមេទ្វារខាងជើង គឺទទួលការបកប្រែជាភាសាបារាំងដោយ៖

- Cœdès, G., 1954, *Inscriptions du Cambodge*, vol.VI, p.72.

ក្រោយមកទៀតមានការសិក្សាលម្អិតមួយអំពីរូបព្រះហរិហរ ដែលតាមស្នាទមើលទៅប្រហែលជាបដិមាដើមនៃប្រាសាទនេះតែម្តង។ ការសិក្សានោះធ្វើដោយ ៖

- Régnier, Rita, 1966, " Note sur l'évolution du chignon (jata) dans la statuaire préangkorienne ", *Arts Asiatiques*, t. XIV, p.17-40.

ចំណែកឯសំណល់ពីចុងសម័យកណ្តាលមកដែលមាននៅប្រាសាទនេះ គឺសន្លឹកទ្វារឈើដែលមានចម្លាក់។ បើនៅសម័យថ្មីវិញ គេសង្កេតឃើញថានៅទសវត្ស១៩៦០ ក៏មានចម្លាក់គូរជាទីចាប់អារម្មណ៍។ ទាំងអស់នេះសិក្សាឡើងដោយ៖

- Giteau, M., 1975, *Iconographie du Cambodge post-angkorien*, EFEO, p.16, 39, 205, 207, 263, Pl. XL, photos 68, 95.

នៅទីនេះខ្ញុំពុំធ្វើការសិក្សាលម្អិតម្តងទៀតទេ ត្បិតគោលបំណងរបស់ខ្ញុំគឺចង់រំលឹកពីសារសំខាន់នៃតំបន់ទាំងមូលនៅមុនសម័យអង្គរ ដោយយកចំណុច ភូមិសាស្ត្រល្អិតតូចមួយនេះមកធ្វើជាគោល។

## សម័យកាលនៃប្រាសាទ

### - ក្បាច់លំអ

ជាទូទៅគេតែងយកក្បាច់លំអ ដែលមាននៅលើសំណង់ ជាពិសេសហោជាង, ផ្តែរនិងសសរមកធ្វើជាទីពិចារណា។ ប្រាសាទ ដែលយើងពោលនេះមិនឃើញមានហោជាង នៅសល់ទេ ប៉ុន្តែផ្តែរព្រមទាំងសសរដែលនៅ ទ្វារចូលខាងកើតនៅមាន ភាពពេញលេញ។ គ្រឿងទ្វារទាំងពីរនេះ សុទ្ធតែនៅក្នុងរចនាបទមុនអង្គរ ជាពិសេសបើយើងគិតថាផ្តែរនេះនៅក្នុងរចនាបទ “កំពង់ព្រះ” សុទ្ធសាធនោះ គឺមានន័យថាប្រាសាទនេះសាងឡើងនៅស.វ.ទី៨ (រូបលេខ៥_៦)។



រូបលេខ ៥



រូបលេខ ៦

### - សិលាចារឹក

សំណាងល្អ ប្រាសាទនេះមានបន្សល់ទុកលើមេទ្វាររបស់ខ្លួននូវសិលាចារឹកមួយផ្ទាំង ដែលមួយភាគនៅអានបាន ហើយដែលក្នុងនោះឃើញមានកាលបរិច្ឆេទ “៦២៨សក” គឺត្រូវនឹង គ.ស. ៧០៦ (រូបលេខ៧)។



រូបលេខ៧



រូបលេខ៨



រូបលេខ៩

_ បដិមា

ដូចទើបនឹងឃើញស្រាប់ សិលាចារឹកនោះពោលពីដង្វាយដែលធ្វើឡើងចំពោះទេព "ហរិហរ" ដែលមាន នៅក្នុងនោះ។ ទេពនោះមានប្រាកដមែន ហើយក៏មិនបាត់បង់ទៅណាដែរ ព្រោះគេបានឃើញ ហើយយកទៅរក្សាទុកនៅសារមន្ទីរជាតិសព្វថ្ងៃ (រូបលេខ៨_៩)។ ដូច្នេះតឹកតាងអ្វីៗដែលមានមកសឹងតែស្របគ្នាទាំងស្រុង ហើយបញ្ជាក់ថាប្រាសាទនេះសាងឡើងនៅដើមស.វ.ទី៨។ ចំណុចទេពហរិហរនេះគួរឲ្យយកមកពិចារណាដែរ ព្រោះយើងដឹងថាប្រាសាទអណ្ដែតដែលក្បាច់លំអមានលក្ខណៈ ប្រហាក់ប្រហែលគ្នានេះក៏តម្កល់ព្រះហរិហរដូចគ្នា។ តើមានន័យថា នៅតំបន់នេះនាស.វ.ទី៨ ព្រះហរិហរមានគេនិយមគោរពបូជាច្រើនឬអ្វី?

នៅក្នុងបរិវេណវត្តប្រាសាទ យើងឃើញស្លាកស្នាមចំនួន៥ផ្សេងទៀត។ ទួលនីមួយៗដើមឡើយមានប្រាសាទមួយ បើតាមការពិនិត្យដោយភ្នែកទទេ មិនទាន់មានការធ្វើកំណាយ តាមក្បួនខ្នាតបុរាណវិទ្យា (រូបលេខ ១០)។ ពិតមានដែលទាក់ទងនឹងប្រាសាទទាំង៥នេះ ស្ទើរបាត់បង់ទាំងស្រុងទៅហើយ សូម្បីតែឈ្មោះក៏គ្មានផង។

នៅក្រៅបរិវេណវត្តវិញ តែពុំឆ្ងាយប៉ុន្មានពីរបងវត្តឡើយ គឺមានទួលមួយដែលសព្វថ្ងៃអ្នកស្រុកហៅថាទួល "សុពណ៌កាលី" ដែលស្ទើរតែគ្មានសំណល់អ្វីទាំងអស់ក្រៅពីថ្មពីរបីផ្ទាំង (រូបលេខ១១)។ សំណាងល្អមាននៅសល់បំណែកសិលាចារឹកមួយដែលទើបនឹងជីកបានពីក្នុងដី (សព្វថ្ងៃគេយកទៅរក្សាទុកនៅមន្ទីរវប្បធម៌ខេត្តកំពង់ធំ) ។ អក្សរថ្មនោះយើងមើលស្គាល់ថាជាអក្សរមុនសម័យអង្គរ (រូបលេខ១២) ហើយដែលគួរតែអ្នកជំនាញខាងសិលាចារឹកសិក្សាផ្សព្វផ្សាយឲ្យបានជ្រួតជ្រាប ជាទូទៅ។



រូបលេខ១០



រូបលេខ១១



រូបលេខ១២

## - ដំណែលផ្សេងៗទៀតពីសម័យបុរាណ

ចំពោះដំណែលផ្សេងៗទៀតដែលមានពីសម័យបុរាណមក យើងឃើញមានវត្ថុបី ដែលព្រះសង្ឃរក្សាទុក នៅក្នុងវត្ត។ វត្ថុនោះគឺមានលិង្គពីរ ដែលមួយជាមុខលិង្គ (រូបលេខ១៣_១៤)។ រីឯវត្ថុទីបីគឺថ្មសម្រាប់កិនថ្នាំឬគ្រឿងក្រអូប (សំស្ក្រឹតហៅថា "បេសានី")។ ប៉ុន្តែយើងមិនច្បាស់ថាវត្ថុទាំងនេះមកពីប្រាសាទដែលនៅតួពេញលេញនេះឬមកពីទួលជិតៗនោះឡើយ (រូបលេខ ១៥)។



រូបលេខ១៣



រូបលេខ១៤



រូបលេខ១៥

## - ហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធដែលនៅសល់សុទ្ធសឹងទាក់ទងនឹងធារាសាស្ត្រ ក្នុងនោះយ៉ាងហោចណាស់បីមានលក្ខណៈជាបារាយឬល្បើក ពោលគឺជាអាងផ្ទុកទឹកដែលមានតែមជាទំនប់ឬល្បើក ថ្វីត្បិតតែអ្នកស្រុកសព្វថ្ងៃហៅ ថា "ត្រពាំង" ឬ "ស្រះ"។ អាងដែលធំជាងគេមានបណ្តោយប្រវែង ២៦០ម. x ទទឹង ៨០ម.។ ដោយសារផ្លូវជាតិមកកាត់អាងនេះជាពីរកំណាត់ ប៉ែកខាងលិចមានឈ្មោះថា "ត្រពាំងកូនរាយ" រីឯប៉ែកខាងកើតដែលធំជាងនោះគេ ហៅថា "ត្រពាំងដូងង៉ុយ"។ រីឯល្បើកពីរទៀតដែលតូចជាងនោះបន្តិច មួយមានឈ្មោះថា "ត្រពាំងរងស្អត" ឯមួយទៀតហៅថា "ត្រពាំងត្រចៀកជ្រូក"។ យើងមិនអាចដឹងច្បាស់ថាត្រពាំងនិងស្រះទាំងនេះកើតឡើងជំនាន់ជាមួយគ្នា ឬខុសគ្នាឡើយ។ម្យ៉ាងទៀតយើងក៏ពុំអាចអះអាងថាហេដ្ឋារចនាសម្ព័ន្ធដែលនៅសល់នេះ ហើយដែលអ្នកស្រុកនៅបន្តការប្រើប្រាស់រាល់ថ្ងៃមានផ្នែកណាមួយដែលកើតឡើងនៅជំនាន់ប្រាសាទនោះកសាងដែរ (សូម មើលប្លង់ទី២)។



ប្លង់ទី២



រូបលេខ១១៦

## ការវិវឌ្ឍន៍ពេលក្រោយមក

នៅសម័យកណ្ដាល ពុទ្ធសាសនាថេរវាទក៏រីកដុះដាលនៅទីនេះដូចជានៅទីដទៃនៃប្រទេសកម្ពុជាដែរ។ បើយើងមើលទៅគុកកំបុត ឃើញថាវិចិត្រករបានឆ្លាក់រូបព្រះពុទ្ធធំៗក្នុងឥរិយាបថផ្សេងៗគ្នានៅផ្ទាល់លើជញ្ជាំងឥដ្ឋ (រូបលេខ១១៦)។ តែទោះជាគ្មានការកែប្រែរូបរាងប្រាសាទក្ដី ក៏យើងឃើញថាប្រាសាទជាច្រើនមានវត្ថុមកវាតទីនៅលើកន្លែងចាស់របស់ខ្លួនដែរ។ ចំពោះប្រាសាទនៅវត្តប្រាសាទនេះ យើងពុំដឹងថាមានការខូចខាតអ្វីខ្លះទេ ទៅលើបដិមាឬវត្ថុសម្រាប់បូជា ដោយធម្មជាតិក្ដី ដោយមនុស្សក្ដី ក្នុងប៉ុន្មានសតវត្សកន្លងមកនេះ តាំងពីខ្មែរកាន់ព្រះពុទ្ធសាសនាថេរវាទមក។ ប៉ុន្តែមានវត្ថុមួយចំនួនដែលយើងនៅដឹងដានខ្លះ ហើយដែលប្រហែលជាសាងឡើងយ៉ាងចាប់ណាស់ក៏នៅស.វ.ទី១៩ដែរ។ វត្ថុទាំងនេះមានជាអាទិ៍ សន្លឹកទ្វារឈើដែលគេឆ្លាក់រូបប្រុសនៅខាងស្ដាំ ស្រីនៅខាងឆ្វេង ហើយដែលមិនដឹងជាយើងអាចសន្និដ្ឋានថាជាទ្វារបាលបានឬមិនបាន (រូបលេខ១១៧)។ ការដែលគួរកត់សម្គាល់គឺអ្នកស្រុកចាប់អារម្មណ៏លើរូបស្រីនោះខ្លាំងជាងគេ ដោយហៅថា “ស្រីគ្រប់ល័ក្ខណ៏” ហើយតែងបន់ស្រន់រូបនោះហាក់ដូចជាទេពមួយដូច្នោះដែរ[២]។ រីឯបដិមាឈើ ឬថ្មគោល និងស្លឹកសីមាខ្លះដែលចល័តបានវិញ ក៏មានមួយចំនួនដែរ ដែលប្រហែលជាសាងឡើងនៅស.វ.ទី១៩ និង២០ (រូបលេខ១១៨_២៩)។ ម្យ៉ាងទៀត នៅសម័យកណ្ដាលគេបានយកថ្មផ្នែកខ្លះនៃប្រាសាទបុរាណមកកែច្នៃតាមតម្រូវការនៅពេលនោះ។



រូបលេខ១១៧





រូបលេខ១១៨



រូបលេខ១១៩



រូបលេខ១២០

[២] ករណីនេះពុំប្លែកប៉ុន្មានទេ ព្រោះបើយើងយកប្រាសាទនាងខ្មៅនៅក្នុងខេត្តតាកែវមកពិចារណាឃើញថានៅចុងស.វ.ទី១៩ បដិមាដើមនៃប្រាសាទស្ថិតនៅក្នុងតួប៉មទាំងពីរនៅឡើយ។ នៅក្នុងប៉មមួយជាទេពស្រី រីឯក្នុងប៉មមួយទៀតជាទេពប្រុស។ ប៉ុន្តែគេយកចិត្តទុកដាក់តែទៅលើ ទេពស្រីនោះប៉ុណ្ណោះ បានជាប្រាសាទទាំងមូលមានឈ្មោះថា “ប្រាសាទនាងខ្មៅ”។


រូបលេខ២១


រូបលេខ២២


រូបលេខ២៣


រូបលេខ២៤


រូបលេខ២៥


រូបលេខ២៦


រូបលេខ២៧


រូបលេខ២៨


រូបលេខ២៩

ឧទាហរណ៍ គេយកផ្នែកនៃបល្ល័ង្កខ្លះមកធ្វើជាកំណល់សសរព្រះវិហារ ដើម្បីទ្រកុំឲ្យស្រុត និងការពារកុំឲ្យឈើនោះពុកផុយដោយសំណើម ឬសត្វល្អិត (រូបលេខ៣០)។

## សម័យបច្ចុប្បន្ន

ដូចបានបង្ហើបពីខាងលើនេះបន្តិចមក កេរ្តិ៍ដំណែលនៅទីនេះបានទទួលរងខូចខាតដោយដៃមនុស្សនាទសវត្សកន្លងមកថ្មីៗនេះ ដូចជានៅទីដទៃទូទៅនៃប្រទេសកម្ពុជាដែរ។ ប៉ុន្តែបើពោលពីកិត្តិនាមនៃភូមិប្រាសាទនេះវិញឃើញថាពុំទាន់រង្គោះរង្គើខ្លាំងឡើយ។ អ្នកស្រុកនៅតែមានជំនឿលើ " ស្រីគ្រប់ល័ក្ខណ៍ " ថ្វីត្បិតតែរូបនោះបាត់បង់ទៅហើយក៏ដោយ។ រីឯវត្តប្រាសាទក៏ជាវត្ត ដែលមានចំណុះធំជាងគេ។ ចំណុចនេះអាចបញ្ជាក់បានដោយយកការដាក់វេននៅក្នុងរយៈកាលកាន់បិណ្ឌមកជាទីពិចារណា ត្បិតមួយវេន។ ភាគច្រើនគឺភូមិមួយទាំងមូលដែលនៅជុំវិញនោះជាអ្នករ៉ាប់រង (រូបលេខ៣១)។

ដូចអ្នកអានឃើញស្រាប់ ខ្ញុំពុំបានធ្វើការរៀបរាប់ពីភូមិប្រាសាទនេះឲ្យបានពិស្តារឡើយ ត្បិតគោលបំណងរបស់ខ្ញុំគឺគ្រាន់តែចង់ផ្តល់ជាគំនិតពិចារណាលើភាពថ្កុំថ្កើងនៅតំបន់ដែលពោលមកនេះតាំងពីមុនសម័យអង្គររហូតមកដល់សម័យអង្គរ ដោយយកភូមិប្រាសាទនេះធ្វើជាឧទាហរណ៍។ តាមស្មានមើលទៅ សន្ទុះខ្លាំងបង្អស់នៃភាពថ្កុំថ្កើងនោះ ប្រហែលជាកើតឡើងនៅក្នុងបរិបទប្រវត្តិសាស្ត្រស.វ.ទី៧ ដែលមានក្រុមប្រាសាទសម្បូណ៌ព្រៃគុកជាតឹកតាង់ដ៏ជាក់ស្តែង។ គឺតពីនោះមកហើយ ដែលភូមិប្រាសាទព្រមទាំងដំណែលបុរាណផ្សេងៗ ទៀតរីកដុះដាលឡើងជាបន្តបន្ទាប់។



*រូបលេខ១៣០*



*រូបលេខ១៣១*

## ឯកសារពិគ្រោះ

- Aymonier, E., 1900, *Le Cambodge,* I, Ernest Leroux, Paris.

- Lunet de Lajonquière, E., 1902, *Inventaire descriptif des monuments du Cambodge,* I, Ernest Leroux, Paris.

- Parmentier, H., 1927, *L'art khmèr primitif,* Vanoest, Paris, tome premier (texte) et tome second (planches).

- Cœdès, G., 1954, *Inscriptions du Cambodge,* vol.VI, Paris.

- Régnier, Rita, 1966, " Note sur l'évolution du chignon (jata) dans la statuaire préangkorienne ", *Arts Asiatiques,* t. XIV.

- Giteau, M., 1975, *Iconographie du Cambodge post-angkorien,* EFEO, Paris.